ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ ព្រហស្បតិ៍ ១៤ រោច ខែ ស្រាពណ៍ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧*

*រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០២៣*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយក្រុមបេសកកម្ម ស្ថាប័នស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចតំបន់អាស៊ានបូកបី (AMRO)

នាព្រឹកថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០២៣, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលការចូលជួបសម្តែងការគួរសម និងពិភាក្សាការងារពីសំណាក់ក្រុមបេសកកម្មទស្សនកិច្ចប្រចាំឆ្នាំរបស់ស្ថាប័ន ASEAN+3 Macroeconomic Research Office (AMRO) ដែលដឹកនាំដោយលោកប្រធាន **បណ្ឌិត លី គួឈីង** ។

ជាមួយកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះក្រុមការងារ AMRO, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានលើកឡើងពីសារៈសំខាន់នៃបេសកកម្មទស្សនកិច្ចប្រចាំឆ្នាំរបស់ស្ថាប័ន AMRO ដែលតែងសិក្សាវាយតម្លៃអំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា និងផ្តល់អនុសាសន៍សំខាន់ៗ សម្រាប់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយសេដ្ឋកិច្ច និងវិធានការចាំបាច់នានារបស់រាជរដ្ឋាភិបាលកម្ពុជា ។

**ភាគីទាំងពីរ** បានពិភាក្សាអំពីស្ថានភាពសេដ្ឋកិច្ចសកលឆ្នាំ ២០២៣ នេះ ដែលមានភាពធូរស្រាលបន្តិច ហើយដែលត្រូវបានសន្និដ្ឋានចុងក្រោយថានឹងមិនធ្លាក់ទៅក្នុងស្ថានភាពនៃវិបត្តិទេ បន្ទាប់ពីស្ថានភាពសេដ្ឋកិច្ចប្រទេសធំៗមួយចំនួន ដូចជា សហរដ្ឋអាមេរិក បានត្រឡប់មករកស្ថានភាពធូរស្រាលជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងចំណាយប្រើប្រាស់ និងភាពរឹងមាំនៃទីផ្សារការងារ ក្រោយសម្ពាធអតិផរណាត្រូវបានបន្ធូរបន្ថយជាបន្តបន្ទាប់ ។ ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចពិភពលោកហាក់នៅមានភាពផុយស្រួយ និងហ៊ុមព័ទ្ធដោយហានិភ័យ និងភាពមិនប្រាកដប្រជាកាន់តែស្រួចស្រាល់ជាងមុន ដោយសារការកើនឡើងនូវភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងការបែកខ្ញែកច្រវ៉ាក់ផ្គត់ផ្គង់សកល, លទ្ធភាពនៃការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុជាបន្តបន្ទាប់, ការងើបឡើងយឺតជាងការរំពឹងទុកនៃសេដ្ឋកិច្ចចិន និងបម្រែបម្រួលអាកាសធាតុ ជាដើម ។

**លោកបណ្ឌិត លី គួឈីង** ក៏បានកត់សម្គាល់ផងដែរថា សេដ្ឋកិច្ចកម្ពុជា មានការងើបឡើងវិញយ៉ាងឆាប់រហ័ស និងរឹងមាំបន្ទាប់ពីការបើកប្រទេសឡើង ដែលជំរុញដោយសកម្មភាពចាយវាយក្នុងស្រុក និងការកើនឡើងតម្រូវការ

សកល ។ នៅក្នុងឆ្នាំ ២០២៣, AMRO វាយតម្លៃថា សេដ្ឋកិច្ចកម្ពុជានៅរក្សាបានកំណើនក្នុងអត្រា ៥,៣% ដែលជាកំណើនខ្ពស់ក្នុងតំបន់ ទោះបីត្រូវថមថយតិចជាការវាយតម្លៃកាលពីដើមឆ្នាំក្តី ។ កំណើននេះជំរុញដោយការងើបឡើងវិញយ៉ាងឆាប់រហ័សនៃវិស័យទេសចរណ៍, ភាពរឹងមាំនៃវិស័យកម្មន្តសាលមិនមែនកាត់ដេរ និងលំនឹងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ទោះបីមានការថមថយវិស័យកាត់ដេរ និងភាពទ្រឹងនៃវិស័យសំណង់ និងអចលនទ្រព្យក៏ដោយ ។ កត្តាទាំងនេះ បង្ហាញពីលទ្ធផលនៃការបន្តអនុវត្តវិធានការអន្តរាគមន៍នានារបស់រាជរដ្ឋាភិបាល ដើម្បីរក្សាលំនឹងជីវភាព និងសកម្មភាពសេដ្ឋកិច្ចរបស់វិស័យអាទិភាពដែលនៅទទួលរងផលប៉ះពាល់ ។ ទោះបីរាជរដ្ឋាភិបាល បានបង្កើនចំណាយសម្រាប់ការជួយអន្តរាគមន៍ទាំងនេះ ក៏ស្ថានភាពហិរញ្ញវត្ថុសាធារណៈជារួមនៅរក្សាបានចីរភាពតាមរយៈការរក្សានូវវិន័យថវិកា ការចាយចំទិសដៅ ព្រមទាំង ការរក្សាបំណុលសាធារណៈឱ្យនៅកម្រិតទាបអាចគ្រប់គ្រងបាន ។ វិស័យហិរញ្ញវត្ថុក៏នៅមានស្ថិរភាព ទោះបីមានការប៉ះពាល់ខ្លះដោយសារការកើនឡើងនូវអត្រាការប្រាក់គោលជាសកល ។ ទំហំពាណិជ្ជកម្មជារួមមានតុល្យភាពល្អប្រសើរ ដោយសារការថមថយការនាំចេញ ជាពិសេស វត្ថុធាតុដើមផលិត ខណៈដែលការបង្វែរងកជននៅបន្តមានកំណើន ។ ជាមួយគ្នានេះ, លោកបណ្ឌិត **លី គួឈីង** បានលើកឡើងជាអនុសាសន៍មួយចំនួនដូចជា÷

១. កម្ពុជាគួរចាប់ផ្តើមកសាងឡើងវិញនូវទ្រនាប់ថវិកាដើម្បីពង្រឹងភាពធន់នៃហិរញ្ញវត្ថុសាធារណៈ,

២. គួរបន្តតាមដាននិងពង្រឹងភាពធន់នៃវិស័យហិរញ្ញវត្ថុ ដើម្បីធានាស្ថិរភាព និង

៣. ការបន្តពង្រឹងការអនុវត្តគោលនយោបាយរចនាសម្ព័ន្ធ ដើម្បីបង្កើនភាពធន់ និងភាពប្រកួតប្រជែងរបស់កម្ពុជា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានធ្វើការវាយតម្លៃខ្ពស់លើលទ្ធផលនៃកំណើនសេដ្ឋកិច្ច និងបានសម្តែងការគាំទ្រទៅនឹងអនុសាសន៍របស់ក្រុមការងារ AMRO ដើម្បីធានាបានចីរភាពកំណើន និងភាពធន់នៃសេដ្ឋកិច្ចកម្ពុជា ។ និងបានលើកឡើងអំពីទិសដៅគោលនយោបាយរបស់រាជរដ្ឋាភិបាល ដោយផ្តោតលើការពង្រឹងភាពធន់ទាំង ៥ ដូចមានក្នុងយុទ្ធសាស្ត្របញ្ចកោណ- ដំណាក់កាលទី១÷

១. ភាពធន់នៃស្ថាប័នសាធារណៈ,

២. ភាពធន់នៃសេដ្ឋកិច្ច,

៣. ភាពធន់នៃសង្គម,

៤. ភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ និង

៥. ភាពធន់ផ្នែកបរិស្ថាន។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ AMRO ចំពោះការវាយតម្លៃពាក់ព័ន្ធនឹងស្ថានភាព និងទស្សនវិស័យសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាផ្តល់ទស្សនៈ និងអនុសាសន៍នានា សំដៅរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែប្រសើរឡើង និងជូនពរក្រុមការងារឱ្យទទួលបានជោគជ័យ និងផ្លែផ្កាសម្រាប់ការបំពេញបេសកកម្មការងារក្នុងឆ្នាំ ២០២៣ នេះ ។

៚៚៚✵៙៙៙